ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# ស្តីពី

# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២២

នៅក្នុងខែមីនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និង សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារតាមដានការអនុវត្តច្បាប់**

- បានរៀបចំទីកន្លែង និងផ្តល់សេវាជូនគណៈកម្មការទី៩ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត **ទី ថានី** អនុប្រធានទី១ អាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅសាលប្រជុំគណៈកម្មការទី៩ ព្រឹទ្ធសភា

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា៖

+អញ្ជើញជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តិ បញ្ហាប្រឈម និងសំណូមពរនានា នៅខេត្តសៀមរាប

+អញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព នៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

+អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីសិប្បកម្មតម្បាញហូល ផាមួង ក្រម៉ា កញ្ចើ ល្អី នៅខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ

+អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីក្តាប់នូវស្ថានការណ៍ជាក់ស្តែង ពិនិត្យតាមដាន



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oumsarith_sgsenate@gmail.com oumsarith_sgsenate@yahoo.com

យន្តការនៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ អំពីបញ្ហាប្រឈម និងសំណូមពរនានា នៅខេត្តកំពត និងខេត្តកែប

+ អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មាន អំពីវឌ្ឍនភាព និងបញ្ហាផ្សេងៗ នៅខេត្តមណ្ឌលគិរី។

**២- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចូលរួមដង្ហែព្រះរាជដំណើររបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ស្តេចយាងពិនិត្យ និងព្យាបាលព្រះរាជសុខភាព នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន និងអញ្ជើញគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខជាមួយក្រុមគ្រួសារសព អគ្គមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **លឹម ឈុន** ឪពុកបង្កើតឧកញ៉ា **អ៊ីង ប៊ុនហ៊ូវ** ព្រមទាំងចូលរួមបុណ្យសពលោកជំទាវ **ច័ន្ទ ផល្លី** ជាភរិយារបស់ឯកឧត្តមនាយឧត្តមសេនីយ៍ **ឈិន ច័ន្ទពណ៌** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ

- បានផ្តល់សេវា និងអមដំណើរឯក**ឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា ប្រធានស្តីទីព្រឹទ្ធសភា** អញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខណ្ឌ និងប្រធានក្រុមប្រឹក្សាសង្កាត់ នៅខណ្ឌព្រែកព្នៅ ខណ្ឌច្បារអំពៅ ខណ្ឌ៧មករា ខណ្ឌដូនពេញ ខណ្ឌបឹងកេងកង ខណ្ឌឫស្សីកែវ ខណ្ឌទួលគោក ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ ខណ្ឌចំការមន ខណ្ឌដង្កោ ខណ្ឌមានជ័យ និងខណ្ឌកំបូល ដើម្បីឈ្វេងយល់អំពីសភាពការណ៍រួមក្នុងមូលដ្ឋាន ការងារសន្តិសុខ សណ្តាប់ធ្នាប់ ពិនិត្យណែនាំអំពីការផ្តល់សេវាសាធារណៈឱ្យបានល្អ និងការត្រៀមលក្ខណៈសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នាពេលខាងមុខ

- បានផ្តល់សេវា និងអមដំណើរឯក**ឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញជាគណៈអធិបតីក្នុងពិធីសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរ ក្រុមប្រឹក្សាឃុំ-សង្កាត់ ទូទាំងខេត្តកណ្តាល សរុបចំនួន៩១៥នាក់ ព្រមទាំងបានអញ្ជើញចូលរួមក្នុងពិធីបុណ្យពុទ្ធាភិសេក សាមញ្ញាភិសេក ឆ្លងព្រះចេតិយ និងអភិសេករូបបដិមា ឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធលោកជំទាវ **អ៊ូច សំអាត** នៅខេត្តតាកែវ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈមនៃការផ្តល់សេវាសាធារណៈ

គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយអំពីវិធានការរបស់ក្រសួងសុខាភិបាលស្តីពី វិធីការពារខ្លួនពីជំងឺរាតត្បាតកូវីដ-១៩ ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ និងនាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ព្រមទាំងចូលរួមគោរពវិញ្ញាណក្ខន្ធ ចំនួន១៤៤លើក នៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តស្វាយរៀង

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក និងសង្កាត់ព្រែកលៀប ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- ឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរសង្កាត់បាក់ខែង និងសង្កាត់កោះដាច់ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រមទាំងអញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **កូ យ៉ាន** ត្រូវជាម្តាយបង្កើតរបស់ ឯកឧត្តម **ផៃ ប៊ុនឈឿន** រដ្ឋលេខាធិការប្រចាំការក្រសួងបរិស្ថាន នៅខេត្តកណ្តាល និងសពលោក **សៅ ខូខេមា** នៅសង្កាត់បាក់ខែង

- បាននាំយកថវិការបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ចំនួន១០,០០០ដុល្លារសហរដ្ឋអាមេរិក និង២០លានរៀល ជូនកាកបាទក្រហមកម្ពុជា

- បាននាំយកថវិការបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឧបត្ថម្ភដល់សមាគមចលនាវប្បធម៌ដើម្បីកុមារកំព្រា កុមារក្រីក្រចំនួន២,០០០,០០០រៀល

- បានទទួលពាក្យបណ្តឹងចំនួន០៣ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០៦ករណី កំពុងពិនិត្យសិក្សាចំនួន០៦ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០៣ករណី

- បានរៀបចំអំណោយចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

- បានចាត់ចែងបញ្ជូនសារលិខិតថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និងជូនពរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទ

ក្រហមកម្ពុជា ព្រមទាំងឥស្សរជនជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសនៃការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១១១ នៃទិវាអន្តរជាតិនារី ៨មីនា និងចម្រើនជន្មាយុចំនួន០៧លើក

- បានសហការរៀបចំពិធីគោរពវិញ្ញាណក្ខន្ធសពឥស្សរជនជាតិចំនួន០២លើក

- បានធ្វើសាររំលែកទុក្ខជូនគ្រួសារសពមន្ត្រីជាន់ខ្ពស់ចំនួន០៦លើក

- បានផលិតទស្សនាវដ្ដីប្រចាំខែមីនា ឆ្នាំ២០២២ ចំនួន៨០០ក្បាល។

**៣- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទឹកនៃ្ទង និងផ្តល់សេវាក្នុងពិធីជូនសារតាំងជូន **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកឧត្តម Buakeo PHUMVONGSAY ឯកអគ្គរដ្ឋទូត តែងតាំងថ្មី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានរៀបចំទឹកនៃ្ទង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងពិភាក្សាការងារជូនសមាជិក សមាជិកាព្រឹទ្ធសភា ជាមួយប្រតិភូក្រុមប្រឹក្សាភិបាលសាលាអន្តរជាតិប៉ារ៉ាហ្គោន PARAGON International School, លោក Victor Come ជនជាតិអ៊ុយក្រែន និងក្រុមអ្នកវិនិយោគទុនមកពីព្រះរាជាណាចក្រជប៉ុន

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៤(IPU-144) និងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក (ASGP) នៅសាធារណរដ្ឋឥណ្ឌូនេស៊ី ព្រមទាំងចូលរួមប្រជុំស្តាប់បទបង្ហាញនៃការស្រាវជ្រាវរបស់អង្គការ LANDESA និង PIC/PCAsia តាមប្រព័ន្ធវីដេអូ

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យប្រធានសមាគមបេសកកម្មកម្មសិក្សាអាស៊ី មានមូលដ្ឋាននៅទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបពិភាក្សាការងារ និងបានអញ្ជើញចូលរួមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយអគ្គលេខាធិការព្រឹទ្ធសភាបារាំង ស្តីពី សហប្រតិបត្តិការបណ្តុះបណ្តាលធនធានមនុស្ស និងពិធីចុះអនុស្សរណៈជាមួយវិទ្យាស្ថានស្រាវជ្រាវច្បាប់នៃសាកលវិទ្យាល័យ Zurich ស្តីពី ជំនាញស្រាវជ្រាវច្បាប់ និងបានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការជាមួយភាគីបារាំង(APF) និងដៃគូនានា និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍សមាគមអគ្គលេខាធិការសភាពិភពលោក (ASGPF) នៅប្រទេសសេណេហ្កាល់ ព្រមទាំងបានអញ្ជើញបិទវគ្គបណ្តុះបណ្តាល ស្តីពី បច្ចេកទេសក្នុងការតាក់តែងឯកសារសម្រាប់គាំទ្រមហាសន្និបាតអាយ៉ាលើកទី៤៣ តាមប្រព័ន្ធវីដេអូ

- បានរៀបចំជូន កញ្ញា **តង់ សុមនី** អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទទួលគ្រឿងឥស្សរិយយសពីស្ថានទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតចិន, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការមូលនិធិអាស៊ី, សាលាភូមិន្ទរដ្ឋបាល, សាកលវិទ្យាល័យប៊ែលធីអន្តរជាតិ, មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ(HRD), មជ្ឈមណ្ឌលសកាអាស៊ី(PCA), វិទ្យាស្ថាន SalaCyber, វិទ្យាស្ថាន DataU Academy, វិទ្យាស្ថាន CamKPI Professional Academy, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានជាតិ ប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (NIPTICT), ភ្នាក់ងារសន្តិមព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមហ៊ុនCambodia Hosting និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ

## ៤- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បានទទួលសម្ភារឧបករណ៍បច្ចេកទេសព័ត៌មានវិទ្យា ជំហានទី១ ក្រោមការឧបត្ថម្ភគាំទ្ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានប្រជុំពិនិត្យឯកសារ និងរៀបចំដំណើរទស្សនកិច្ចជាផ្លូវការរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** នៅសាធារណរដ្ឋកូរ៉េ

- បានប្រជុំពិនិត្យ និងវាយតម្លៃតម្លើងថ្នាក់បៀវត្សមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំការងារការកែទម្រង់ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធវីដេអូ

- បានប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

### ៤.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានទទួលលិខិតចូលចំនួន២១៩ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៥៦ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានបើកប្រាក់បៀវត្សប្រចាំខែមីនា ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែមីនា ឆ្នាំ២០២២

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មជាវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន៥៥ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន ១៦ប័ណ្ណ

- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលត្រូវពិនិត្យ និង វាយតម្លៃដំឡើងថ្នាក់បៀវត្សប្រចាំឆ្នាំ២០២២

- បានធ្វើដំណើរទៀនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២២

- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានទទួលអាហារូបករណ៍ ចំនួន០៥នាក់ សិក្សានៅសាកលវិទ្យាល័យបញ្ញាជាតិ សាកលវិទ្យាល័យជាតិគ្រប់គ្រង និងសាកល វិទ្យាល័យប៊ែលធីអន្តរជាតិ

- បានផ្សព្វផ្សាយអាហារូបករណ៍សិក្សានៅសាធារណរដ្ឋប្រជាមានិតចិនសម្រាប់ឆ្នាំ២០២២ និងប្រទេសអូស្ត្រាលីសម្រាប់ឆ្នាំ២០២៣ ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៧ប្លង់

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ការបិទថ្នាំនៅតាមជញ្ជាំង អគារសាលប្រជុំពេញអង្គ, ការរៀបចំជួសជុលអាងចិញ្ចឹមត្រី, ត្រួតពិនិត្យដណ្តើរយន្ត ត្រួតពិនិត្យ សត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារ សារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភាចំនួន១១៣គ្រឿង/លើក

- បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន២៧លើក

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមីនា ឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាព ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា

- បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់ នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានទាំង៥ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំត្រីមាសទី១ ឆ្នាំ២០២២។

**៤.២-ការងារសេវាច្បាប់៖**

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្ដីសម្រេច សេចក្ដីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន១៧៧ច្បាប់

- បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០៩ច្បាប់

- បានចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។

**៤.៣-ការងារស្រាវជ្រាវ៖**

- បានសិក្សាស្រាវជ្រាវ និងធ្វើសំយោគឯកសារព័ត៌មានជាតិ និងអន្តរជាតិ តាមវិស័យចំនួន ៤៤អត្ថបទ

- បានតាមដានការកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាល និងសិក្សាស្រាវជ្រាវ ចងក្រងការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន២៨អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមីនា ឆ្នាំ២០២២ ចំនួន០៤ច្បាប់។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេក-វិទ្យាព័ត៌មានចំនួន៥២គ្រឿង។ បានបញ្ចូលព័ត៌មានស្ដីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន ១៣៣ប្រធានបទ

- បានបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤២គ្រឿង

- បានផលិតវីដេអូសមិទ្ធផលព្រឹទ្ធសភាចំនួន០១លើក

- បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន១៧៧ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ បិទប័ណ្ណខ្ទី និងសងសៀវភៅចំនួន១៥២ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៣៦លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១៦លើក

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន ១,៣៨៤ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្ដាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿនល្អ និងរលូន។

**៤.៥-ការងារពិធីការ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២០លើក

- បានតាមដាន និងចងក្រងសេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១៨ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមីនា ឆ្នាំ២០២២ ចំនួន០១ច្បាប់

- បានកសាងជំនួយស្មារតី ធ្វើលិខិតអបអរសាទរ និងលិខិតថ្លែងអំណរគុណ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន១៣លើក។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៤៦ច្បាប់

- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាពចំនួន០៧លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤១ច្បាប់ ស្មើនឹង១៥៥នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០២ច្បាប់ ស្មើនឹង០២នាក់

- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣៣៧លើក

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥១សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៤លើក មានអ្នកចូលរួមចំនួន៣៤២នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២៧៥លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន៣,៣២៤ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៤០ក្បាល អស់ក្រដាសចំនួន២៧,៧៧០សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្រ្តីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន១៣៨លើក ស្មើនឹង៣២៧នាក់។

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន០៨លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន១៨៧លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០៥លើក។

## III-**ទិសដៅការងារខែមេសា ឆ្នាំ២០២២**

**-បន្តអនុវត្តវិធានការ "៣ការពារ ៣កុំ" ពាក់ម៉ាស់ ធ្វើតេស្តពេលចាំបាច់ និងវិធានការចាំបាច់ផ្សេងៗទៀត (ដាក់ឱ្យនៅដាច់ដោយឡែក រឺចត្តាឡីស័ក) ប្រឆាំងនឹងជំងឺកូវីដ-១៩ និងបន្តយកចិត្តទុកដាក់ធ្វើការងារមនុស្សធម៌ក្នុង និងក្រៅស្ថាប័នឱ្យបានទាន់ពេលវេលា៖**

+យកចិត្តទុកដាក់តាមដានសុខភាពរបស់សមាជិកព្រឹទ្ធសភា

+យកចិត្តទុកដាក់តាមដានសុខភាព លក្ខខណ្ឌការងារ និងជីវភាពទូទៅក្នុងក្របខណ្ឌស្ថាប័នទាំងមូល

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-

វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារៗ វត្តមានមន្ត្រី បុគ្គលិកប្រចាំថ្ងៃអនុវត្តផ្អែកលើការជាក់ស្តែង "វត្តមានខ្លះ ធ្វើការពីចម្ងាយខ្លះ" តាមតម្រូវការ និងលក្ខណៈសម្បត្តិរបស់អង្គភាពនីមួយៗដើម្បីៈ**

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

- ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់សមាជិកព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាល ចាប់ពីខែមេសា ដល់ខែកក្កដា ឆ្នាំ២០២២

- បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា

- ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ មានរបៀបវារៈដូចខាងក្រោមៈ

១-សេចក្តីព្រាងច្បាប់ស្តីពី ការការពាររុក្ខជាតិ និងភូតគាមអនាម័យ

២-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១៤០ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

៣-សេចក្តីព្រាងច្បាប់ស្តីពី សុវត្ថិភាពម្ហូបអាហារ

៤-បញ្ហាផ្សេងៗ។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាៈ

+គណៈកម្មការទី១ អញ្ជើញចុះបេសកកម្ម នៅខេត្តតាកែវ និងខេត្តបាត់ដំបង (ថ្ងៃទី០១ និង០៤-០៦ ខែមេសា ឆ្នាំ២០២២)

+គណៈកម្មការទី២ អញ្ជើញចុះបេសកកម្ម នៅខេត្តព្រះសីហនុ (ថ្ងៃទី០៨-០៩ ខែមេសា ឆ្នាំ២០២២)

+គណៈកម្មការទី៣ អញ្ជើញចុះបេសកកម្ម នៅខេត្តកំពង់ស្ពឺ (ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២)

+គណៈកម្មការទី៥ អញ្ជើញចុះបេសកកម្ម នៅខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកំពត (ថ្ងៃទី០២-០៩ ខែមេសា ឆ្នាំ២០២២)

+គណៈកម្មការទី១០ អញ្ជើញចុះបេសកកម្ម នៅខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង (ថ្ងៃទី២៥-៣០ ខែមេសា ឆ្នាំ២០២២)។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋកូរ៉េ

-ត្រៀមរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCA) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ឡើងវិញជាមួយដៃគូសំខាន់ៗរបស់មជ្ឈមណ្ឌលសភាអាស៊ី(PCA) លេខាធិការដ្ឋាន(APF) លេខាធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ)

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធីបណ្តុះបណ្តាលជាបន្តបន្ទាប់

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-ត្រៀមចុះអនុស្សរណៈជាថ្មីជាមួយរដ្ឋសភាបារាំង

-ត្រៀមរៀបចំសិក្ខាសាលាជាមួយ (APF)ស្ដីពី សេរីភាពសារព័ត៌មាន និងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ (ថ្ងៃទី០៤-១០ ខែមេសា ឆ្នាំ២០២២)

-ត្រៀមទទួលគណៈប្រតិភូដឹកនាំដោយឯកឧត្ដម VINCENT EBLE ប្រធានក្រុមមិត្តភាពសមាជិកព្រឹទ្ធសភាបារាំង-កម្ពុជា និងជាអនុប្រធានគណៈកម្មការហិរញ្ញវត្ថុនៃព្រឹទ្ធសភាបារាំង មកបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា នាខែឧសភា ឆ្នាំ២០២២

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ (IPU, APF, AIPA...)។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ការរៀបចំបែបបទស្នើសុំជំនួយពីរាជរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ

-ត្រៀមរៀបចំយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងគម្រោងថវិកាឆ្នាំ២០២៣

-តាមដាន និងសម្របសម្រួលជាមុនជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីគម្រោងស្នើកសាងអគារថ្មី២ខ្នង

-ត្រៀមផលិត និងផ្សព្វផ្សាយសារជូនពររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែមេសា ឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា

-យកចិត្តទុកដាក់អនុវត្តគោលការណ៍ 3E's ដោយផ្ដោតលើការងារជាអាទិភាព សំខាន់ចាំបាច់ និងបន្ទាន់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ធ្វៀតបញ្ចូលការប្រើប្រាស់គ្រឿងយន្តអគ្គិសនី និងពង្រីកការបំភ្លឺដោយថាមពលព្រះអាទិត្យ ដើម្បីថែរក្សាធម្មជាតិបៃតង កាត់បន្ថយចំណាយ និងការប្រើកម្លាំងមនុស្ស ហើយចាប់ផ្ដើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-ត្រៀមរៀបចំជួសជុលកែលម្អបន្ទប់សម្រាប់អ្នកសារព័ត៌មាន នៅក្រោយអគារក្រហម

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ តម្រូវការ និងការប្រឈម

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការអនុវត្តផែនការបណ្តុះបណ្តាលធនធានមនុស្សតាមកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា

-ការប្រជុំពីចម្ងាយ ការធ្វើការពីចម្ងាយ និងការរៀនសូត្រពីចម្ងាយ គឺជាឧបករណ៍ថ្មី វិធីសាស្ត្រថ្មីក្នុងបរិបទកូវីដ-១៩ ហើយអាចនៅបន្តក្រោយជំងឺកូវីដ-១៩

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ទំនាក់ទំនង និងជំរុញសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន គម្រោងជំនួយក្នុងការសាងសង់អគារសាលប្រជុំពេញអង្គថ្មី និងបំពាក់សម្ភារមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានវិទ្យា(ICT)

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានាៗល។)

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-បន្តការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមន។

IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែមីនានេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បង្កើនការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការផ្តល់សេវាតាមគន្លងថ្មីជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនបានយ៉ាងល្អប្រសើរតាមតម្រូវការចាំបាច់ជាក់ស្តែង ប្រកបដោយភាពទទួលខុសត្រូវតាមមុខសញ្ញារៀងៗខ្លួនៗ ជាពិសេស ក្នុងបរិបទនៃដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានផ្តល់សេវាជូនគណៈកម្មការជំនាញទាំង១០ ចុះបំពេញបេសកកម្ម ជួបសវនាការការងារជាមួយក្រសួង និងស្ថាប័ននានា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធ ចុះជួបសំណេះ-សំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាមួយជំងឺកូវីដ-១៩ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយគណៈប្រតិភូអន្តរជាតិ ជាពិសេសដំណើរបេសកកម្មនៅសាធារណរដ្ឋបារាំង ទទួលបានលទ្ធផលល្អជាសក្តានុពលថ្មីបន្ថែមទៀត ដើម្បីជំរុញសហប្រតិបត្តិការទ្វេភាគី និងពហុភាគីមានលក្ខណៈទាក់ទាញជាងមុនៗ។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២
**អគ្គលេខាធិការ**

**អ៊ុំ_សារិទ្ធ**